អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២១

# <u>សេចក្តីប្រកាសព័ត៌មាន</u>

## អ.វ.ត.ក សហការរៀបចំការប្រកួតប្រជែងតុលាការនិម្មិតផ្នែកច្បាប់មនុស្សធម៌ នៅវគ្គជម្រុះថ្នាក់ជាតិរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC)

ថ្ងៃនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានសហការរៀបចំការប្រកួតប្រជែងតុលាការនិម្មិតផ្នែកច្បាប់មនុស្សធម៌អន្តរជាតិ (International Humanitarian Law Moot Court Competition) នៅវគ្គជម្រុះថ្នាក់ជាតិ ដែលរៀបចំដោយគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ។

បណ្តានិស្សិតដែលបានចូលរួមប្រកួតប្រជែងមានចំនួន ៤ ក្រុម មកពីសាកលវិទ្យាល័យនានាបានឈានទៅដល់វគ្គពាក់កណ្តាលផ្តាច់ព្រ័ត និងវគ្គផ្តាច់ព្រ័ត ដែលត្រូវបានរៀបចំនៅក្នុងបរិវេណបន្ទប់សវនាការ អ.វ.ត.ក ដោយអនុវត្តតាមលក្ខខណ្ឌសុវត្ថិភាពនៃជំងឺកូវីដ-១៩។ មានសាស្ត្រាចារ្យជនជាតិខ្មែរ និងបរទេស និងអ្នកប្រកបវិជ្ជាជីវៈច្បាប់ចំនួនប្រាំពីររូប បានបំពេញមុខងារជាអ្នកវិនិច្ឆ័យក្នុងការប្រកួតប្រជែងនេះ។ ក្រុមដែលទទួលជ័យជម្នះ រួមមានកញ្ញា ម៉ាក ពុធវរៈនុត កញ្ញា គឹម រូសាលីណា និងលោក សុខ ច័ន្ទវិជ័យសម្បត្តិ នឹងបន្តទៅចូលរួមប្រកួតប្រជែងតុលាការនិម្មិតផ្នែកច្បាប់មនុស្សធម៌អន្តរជាតិរបស់កាកបាទក្រហមអាស៊ី-ប៉ាស៊ីហ្វិក ដែលរៀបចំនៅទីក្រុងហុងកុង។

លោកស្រី Dena FISHER ជាប្រធានបេសកកម្មប្រចាំតំបន់មេគង្គរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ មានប្រសាសន៍ថា៖ "វាជាកិត្តិយសដ៏ធំធេងណាស់ ដែលយើងអាចរៀបចំការប្រកួតប្រជែងតុលាការនិម្មិតផ្នែកច្បាប់មនុស្សធម៌អន្តរជាតិ នៅវគ្គផ្តាច់ព្រ័តនៅ អ.វ.ត.ក និងបានឃើញពីសមត្ថភាពដ៏គួរឱ្យកោតសរសើររបស់ប្អូនៗនិស្សិតនៅក្នុងបន្ទប់សវនាការ។

"ច្បាប់មនុស្សធម៌អន្តរជាតិដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ និងពិធីសារបន្ថែមនានារបស់អនុសញ្ញាទាំងនេះ គឺជាបណ្តុំវិធាននានាដែលមានគោលបំណងទប់ស្កាត់នូវទុក្ខវេទនារបស់មនុស្សជាតិ និងបញ្ចៀសកុំឱ្យកើតមានអំពើឃោរឃៅបំផុតដោយសារសង្គ្រាម។ ការរៀបចំព្រឹត្តិការណ៍នៅឆ្នាំនេះ អ.វ.ត.ក

បានផ្តល់ឱកាសពិសេសដល់អនាគតអ្នកច្បាប់កម្ពុជាជំនាន់ក្រោយ ក្នុងការសម្រេចទេពកោសល្យវិជ្ជាជីវៈរបស់ខ្លួន ក្នុងការដោះស្រាយចំពោះការរំលោភបំពានច្បាប់មនុស្សធម៌អន្តរជាតិនាពេលអនាគត នៅទីកន្លែងមួយដែលបង្កើតឡើងដើម្បីធ្វើការស៊ើបអង្កេតទៅលើអំពើឃោរឃៅនានាពីអតីតកាល។

“គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ អ.វ.ត.ក ដែលបន្តឧបត្ថម្ភគាំទ្រដល់គំនិតផ្តួចផ្តើមនេះ និងបានផ្តល់នូវបទពិសោធន៍បំផុសស្មារតីដល់ប្អូនៗនិស្សិតដែលខិតខំប្រឹងប្រែងចូលរួមការប្រកួតប្រជែងនៅថ្ងៃនេះ។ ខ្ញុំសូមសម្តែងការអបអរសាទរដល់អ្នកច្បាប់វ័យក្មេងទាំងអស់របស់យើង ដែលបានជោគជ័យដល់វគ្គផ្តាច់ព្រ័ត្រក្នុងការប្រកួតប្រជែងនេះ និងសូមជូនពរឲ្យពួកគេទទួលបានជោគជ័យថែមទៀតនាពេលអនាគត”។

អ.វ.ត.ក សូមអបអរសាទរដល់ប្អូនៗនិស្សិតទាំងអស់ដែលបានចូលរួម និងបានខិតខំប្រឹងប្រែងលើកកម្ពស់គោលការណ៍សំខាន់ៗនៃច្បាប់មនុស្សធម៌អន្តរជាតិ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក នេត្រ ភក្ត្រា**

ប្រធានផ្នែកកិច្ចការសាធារណៈ និងជាអ្នកនាំពាក្យ

ទូរស័ព្ទ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦

អ៊ីមែល៖ neth.phektra@eccc.gov.kh